

# ប្រទេសកម្ពុជា

# បច្ចុប្បន្នភាពទីផ្សារ

ខែមករា ឆ្នាំ២០២២

## ផ្ដោតលើ៖ ឥទ្ធិពលនៃកូវីដ-១៩ លើតម្លៃស្បៀងអាហារ

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ
ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បុព្វកថា

ការរាតត្បាតនៃកូវីដ-១៩ បានវិវត្តយ៉ាងឆាប់រហ័សពាសពេញពិភពលោក ចាប់តាំងពីដើមឆ្នាំ២០២០មក។ នៅថ្ងៃទី១១ ខែមីនា អង្គការសុខភាពពិភពលោកបានចាត់ទុកកូវីដ-១៩ថាជាជំងឺរាតត្បាតសកល។ ការរាតត្បាតនៃកូវីដ-១៩ បានជះឥទ្ធិពលលើសេដ្ឋកិច្ចពិភពលោកយ៉ាងខ្លាំង។ ជំនួញ និងការធ្វើដំណើរនានាត្រូវបានហាមឃាត់យ៉ាងតឹងរឹង ហើយប្រទេសជាច្រើនរាប់ទាំងប្រទេសកម្ពុជា និងប្រទេសដទៃទៀតនៅអាស៊ី បានអនុវត្តវិធានការបិទការចេញចូលប្រទេស ដើម្បីមិនឲ្យមានការរីករាលដាល។ ចាប់តាំងពីខែមេសា ឆ្នាំ២០២១មក កម្ពុជាបានបិទខ្ទប់ទាំងស្រុង និង/ឬផ្នែកខ្លះនៃរាជធានី/ខេត្តជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់ការរាលដាលនៃព្រឹត្តិការណ៍សហគមន៍ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១។ បើទោះជារដ្ឋាភិបាលបានបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ជាផ្លូវការក្នុងខែធ្នូ ឆ្នាំ២០២១ ក្តី តែក្តីបារម្ភពីមេរោគបម្លែងថ្មីអូមីក្រុងកំពុងកើនឡើង។

ដើម្បីស្វែងយល់ពីឥទ្ធិពលនៃការរាតត្បាតកូវីដ-១៩ លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀងនៅតាមផ្សារនានាក្នុងប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក (WFP) តាមដានតម្លៃលក់ដុំ និងលក់រាយរបស់ស្បៀងអាហារសំខាន់ៗ (ឧបសម្ព័ន្ធទី១ និងទី២) នៅក្នុងផ្សារចំនួន៩៥ ទាំងទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលព័ត៌មានលម្អិតនៅផ្នែកវិធី សាស្រ្ត)។ ជាមធ្យម ប្រធានផ្សារ និងអាជីវករចំនួន ៣៥០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍ តាមរយៈទូរស័ព្ទដែលអនុវត្តដោយក្រុមហ៊ុនចុះកិច្ចសន្យាជាមួយ WFP។ បន្ថែមទៅលើតម្លៃ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស់ទីផ្សារ ដែលរួមបញ្ចូលទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។ ព័ត៌មានផ្សេងទៀតក៏ត្រូវបានប្រើ ដើម្បីបកស្រាយលទ្ធផល និងស្វែងយល់ពីបរិបទកាន់តែទូលំទូលាយ។

ការធ្វើបច្ចុប្បន្នភាពនេះ គឺផ្អែកលើទិន្នន័យ ដែលបានប្រមូលនៅក្នុងសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែ។ តម្លៃជាក់ស្តែងត្រូវបានបង្ហាញក្នុងរបាយការណ៍នេះ។

ប្រព័ន្ធតាមដាននេះគឺផ្អែកលើកិច្ចសហការក្នុងរយៈពេលវែងរវាង WFP និងការិយាល័យទីផ្សារកសិកម្ម (AMO) នៃនាយកដ្ឋានផែនការនិងស្ថិតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។

# មាតិកា


1. **របកគំហើញសំខាន់ៗ** 3

2. **លទ្ធផល**
   - ការដំណើរការរបស់ផ្សារ 4
   - ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រកួន 5
   - ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា 6
   - ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារ 7
   - ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃ នៅជនបទ និងទីប្រជុំជន 8
   - ថ្នាក់ក្រោមជាតិ៖ បម្រែបម្រួលតម្លៃអង្ករចម្រុះ និងស៊ុតទា 9
   - ថ្នាក់ក្រោមជាតិ៖ បម្រែបម្រួលតម្លៃត្រីផ្ទក់ និងប្រេងឆា 10

3. **បរិបទ**
   - ពាណិជ្ជកម្ម និងផលិតកម្មក្នុងស្រុក 11
   - ការឆ្លើយតបផ្នែកនយោបាយ 12

4. **វិធីសាស្រ្ត និងទីតាំងផ្សារ** 13

5. **ឧបសម្ព័ន្ធទី១**
   - បម្រែបម្រួលថ្លៃលក់រាយ 14

6. **ឧបសម្ព័ន្ធទី២**
   - បម្រែបម្រួលថ្លៃលក់ដុំ 15

7. **ឧបសម្ព័ន្ធទី៣**
   - តម្លៃនៃកញ្ចប់ស្បៀងអាហារ 16

8. **ឧបសម្ព័ន្ធទី៤**
   - របាយប្រជាជន និងផ្ទៃដីដាំដុះដំណាំស្រូវ ប្រតិទិនរដូវកាល 17

# របកគំហើញសំខាន់ៗ

## កូវីដ-១៩ និងកត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

ជំងឺកូវីដ-១៩នៅតែបន្តរាតត្បាត និងជះឥទ្ធិពលទៅលើសេដ្ឋកិច្ចពាសពេញពិភពលោក។ មានករណីឆ្លងកូវីដ-១៩ចំនួនច្រើនជាង ៣៧៦ លាននាក់ និងអ្នកស្លាប់លើសពី ៥,៦ លាននាក់ នៅទូទាំងពិភពលោក (អង្គការសុខភាពពិភពលោក ថ្ងៃទី១ ខែកុម្ភៈឆ្នាំ២០២២)។ ចាប់តាំងពីរកឃើញមានឆ្លង ១ករណីនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ នៅ**កម្ពុជា**មានចំនួនអ្នកឆ្លងកូវីដ-១៩ សរុបទាំងអស់ **១២១.៣៩០ នាក់** និងមានករណីស្លាប់ចំនួន **៣.០១៥ នាក់** នៅទូទាំងប្រទេស (ក្រសួងសុខាភិបាល ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២)។ យុទ្ធនាការចាក់វ៉ាក់សាំងត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ដោយរដ្ឋាភិបាលដោយឥតគិតថ្លៃ។ ការចាក់វ៉ាក់សាំងដូសជំរុញទី៤ ត្រូវបានរៀបចំឡើងក្នុងខែមករា ឆ្នាំ២០២២ ឆ្លើយតបទៅនឹងការកើនឡើងករណីឆ្លងមេរោគអូមីក្រុង។

ផ្អែកតាមរបាយការណ៍ថវិកាសង្ខេបឆ្នាំ២០២២របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ចេញផ្សាយនាដើមខែកុម្ភៈ ឆ្នាំ២០២២ អត្រាអតិផរណាព្យាករក្នុងឆ្នាំ២០២២គឺ ២,៨% ធ្លាក់ចុះពី ៣,៤% ក្នុងឆ្នាំ២០២១ ហើយ GDP ព្យាករថានឹងកើនឡើង ៤,៨% ក្នុងឆ្នាំ២០២២ កើនពី ២,៤% ក្នុងឆ្នាំ២០២១។ GDP សម្រាប់មនុស្សម្នាក់រំពឹងថានឹងកើនពី ១.៧៣០ ដុល្លារ ក្នុងឆ្នាំ២០២១ ទៅ ១.៨៤២ ដុល្លារ ក្នុងឆ្នាំ២០២២ (MEF ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២)។

## វិភាគនិន្នាការតម្លៃស្បៀងថ្នាក់ជាតិ (មករា ២០២១ - មករា ២០២២)

**តម្លៃកញ្ចប់ស្បៀងអាហារមាននិន្នាការកើនឡើងថេរក្នុងឆ្នាំ២០២១ តែបានធ្លាក់ចុះក្នុងខែមករា ឆ្នាំ២០២២** ដល់ ១០៣.៣៥៨ រៀល/ម្នាក់/ខែ (-៦,៩% ធៀបនឹងខែមុន និងមិនមានការប្រែប្រួលបើធៀបឆ្នាំមុន)។

**តម្លៃស្បៀងអាហារសំខាន់ៗ**ដែលបានតាមដានបាន**ធ្លាក់ចុះពីខែធ្នូ ឆ្នាំ២០២១ ដល់ខែមករា ឆ្នាំ២០២២** (ការប្រែប្រួលប្រចាំខែ) ពិសេសត្រកួន (-២៣,០%)។

**តម្លៃស្បៀងសំខាន់ៗធៀបនឹងឆ្នាំមុន បានកើនឡើងតិចតួច** (ត្រកួន ស៊ុតទា ត្រីផ្ទក់) រហូតដល់**កើនឡើងខ្លាំង** (ប្រេងឆា)។ តម្លៃអង្ករ និងសាច់ជ្រូកបានថយចុះបន្តិចក្នុងខែមករា ឆ្នាំ២០២២ បើធៀបនឹងខែដដែលកាលពីឆ្នាំមុន។

- តម្លៃអង្ករចម្រុះ៖ -០,៨% **ធៀបខែមុន** និង -២,៩% **ធៀបឆ្នាំមុន**
- តម្លៃត្រកួន៖ -២៣,០% **ធៀបខែមុន** តែ +៧,៣% **ធៀបឆ្នាំមុន**
- តម្លៃស៊ុតទា៖ -៥,៨% **ធៀបខែមុន** តែ +៥,៩% **ធៀបឆ្នាំមុន**
- តម្លៃត្រីផ្ទក់៖ -១,៣% **ធៀបខែមុន** តែ +១០,០% **ធៀបឆ្នាំមុន**
- តម្លៃសាច់ជ្រូក៖ -២,០% **ធៀបខែមុន** និង -១៥,០% **ធៀបឆ្នាំមុន**
- តម្លៃប្រេងឆា៖ +០,៧% **ធៀបខែមុន** និង +៣៦,០% **ធៀបឆ្នាំមុន**

## បម្រែបម្រួលតម្លៃស្បៀងប្រចាំខែថ្នាក់ក្រោមជាតិ (មករា ២០២២)

ក្នុងខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយស្បៀងអាហារសំខាន់ៗ (លើកលែងប្រេងឆា) នៅជនបទទាបជាងនៅទីប្រជុំជន។

ទិន្នាការបម្រែបម្រួលតម្លៃស្បៀងអាហារនៅក្នុងរយៈពេល១ខែ សម្រាប់ស្បៀងអាហារសំខាន់ៗ (លើកលែងប្រេងឆា) មានទិសដៅដូចគ្នារវាងផ្សារនៅជនបទ និងនៅទីប្រជុំជន។ តម្លៃប្រេងឆាបានកើនឡើងនៅជនបទ តែធ្លាក់ចុះនៅទីប្រជុំជន។ តម្លៃអង្ករ សាច់ជ្រូក ត្រីផ្ទក់ ស៊ុតទា និងត្រកួន បានថយចុះទាំងនៅជនបទ និងនៅទីប្រជុំជន។

ស្បៀងអាហារសំខាន់ៗមួយចំនួន ដូចជា៖ អង្ករចម្រុះ ត្រីផ្ទក់ ស៊ុតទា និងប្រេងឆា ក្នុង**ខេត្តព្រៃវែង ខេត្តមណ្ឌលគិរី ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ** មានតម្លៃខ្ពស់ជាងគេបំផុត។

*សន្និដ្ឋាន៖*

នៅដើមខែមករា ឆ្នាំ២០២២ ចំនួនអតិថិជនមកផ្សារបានកើនឡើងបង្គួរធៀបនឹងចុងខែធ្នូ ឆ្នាំ២០២១ **មុនពេលធ្លាក់ចុះបន្តិចជាថ្មីម្តងទៀតនៅចុងខែមករា ដែលទំនងជាបណ្តាមកពីការកើនឡើងចំនួនអ្នកឆ្លងមេរោគកូវីដ-១៩បម្លែងថ្មី*អូមីក្រុង*។** ក្នុងខែមករា ឆ្នាំ២០២២ **តម្លៃកញ្ចប់ស្បៀងអាហារបានធ្លាក់ចុះ ៦,៩% បើធៀបនឹងខែធ្នូ ឆ្នាំ២០២១** ដោយសារតែការធ្លាក់ចុះតម្លៃមធ្យមលក់រាយស្បៀងអាហារសំខាន់ភាគច្រើនបើធៀបនឹងខែមុន។ **និន្នាការធ្លាក់ចុះនេះទំនងជានឹងបន្ត ព្រោះរដ្ឋាភិបាលទើបតែប្រកាសលើកលែងពន្ធសម្រាប់ស្បៀងអាហារមូលដ្ឋាន** ចាប់ពីខែមករា ឆ្នាំ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៣ ជាមួយនឹងការបន្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រដ្ឋាភិបាលរហូតដល់ខែកញ្ញា ឆ្នាំ២០២២។

# ការដំណើរការរបស់ផ្សារ

ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារទាំង៤៥ ដែលបានតាមដានតម្លៃនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍ស្តីពីភាពមានស្បៀង និងការផ្គត់ផ្គង់ស្បៀងអាហារនៅក្នុងផ្សារ ព័ត៌មានអំពីដំណើរការរបស់ផ្សារ និងភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ ក៏ដូចជាចំនួនអតិថិជនទៅផ្សារត្រូវបានប្រមូលនៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣។ **ក្នុងសប្តាហ៍ទី៣ខែមករា ឆ្នាំ២០២២ ចំនួនអតិថិជនទៅផ្សារបានធ្លាក់ចុះបន្តិច បន្ទាប់ពីមានភាពល្អប្រសើរបន្តិចក្នុងសប្តាហ៍ទី១ខែមករា។** នៅពេលសួរអំពីបញ្ហាផ្គត់ផ្គង់ស្បៀងក្នុងផ្សារតាំងពីខែមុន **៥,0%** នៃប្រធានផ្សារ/អ្នកលក់បានរាយការណ៍ពី**ការកើនឡើងនូវតម្លៃផ្គត់ផ្គង់ស្បៀងអាហារ**ក្នុងសប្តាហ៍ទី៣ខែមករា ឆ្នាំ២០២២ ដែលតួលេខនេះបានថយចុះបើធៀបនឹងខែធ្នូ ឆ្នាំ២០២១ ដែលមាន ២៤,០%។ តិចជាង **២,0%** នៃប្រធានផ្សារ/អ្នកលក់បានរាយការណ៍ពី**ការធ្លាក់ចុះគុណភាពស្បៀង និងការថយចុះការផ្គត់ផ្គង់។**




**បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ**

*[1]តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។*

# **ថ្នាក់ជាតិ៖** និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ជារួម តម្លៃមធ្យមលក់រាយថ្នាក់ជាតិស្បៀងអាហារ ដែលបានទទួលទានជាទូទៅចំនួន៣ ប្រភេទ (អង្ករចម្រុះ ស៊ុតទា ត្រកួន[1]) មាននិន្នាការចម្រុះ ដែលតម្លៃអង្ករចម្រុះបានថយចុះ ខណៈតម្លៃស៊ុតទា និងត្រកួនបានកើនឡើងចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២១។ ក្នុងខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយអង្ករចម្រុះ ស៊ុតទា និងត្រកួន បានថយចុះបើធៀបនឹងខែធ្នូ ឆ្នាំ២០២១។ តម្លៃមធ្យមលក់រាយ**អង្ករចម្រុះ** គឺ ២.០១៩ រៀល/គក **ថយចុះ ០,៨% ធៀបនឹងខែមុន និង ២,៩% ធៀបខែដដែលកាលពីឆ្នាំមុន។** តម្លៃមធ្យមលក់រាយ**ត្រកួន**គឺ ៣,០៩៧ រៀល/គក **ទាបជាងខែមុន ២៣,១% តែខ្ពស់ជាងខែដដែលកាលពីឆ្នាំមុន ៧,៣%**។ តម្លៃមធ្យមលក់រាយ**ស៊ុតទា**គឺ ៤.៦៥១ រៀល/១០គ្រាប់ គឺ**ទាបជាងខែមុន ៥,៨% តែខ្ពស់ជាងខែដដែលកាលពីឆ្នាំមុន ៥,៩%**។ សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។




[1]ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។

[2]ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ជារួម តម្លៃមធ្យមលក់រាយថ្នាក់ជាតិស្បៀងអាហារ ដែលបានទទួលទានជាទូទៅដទៃទៀតដូចជា៖ ត្រីផ្ទក់ និងប្រេងឆា បង្ហាញនិន្នាការកើនឡើង ខណៈតម្លៃសាច់ជ្រូកបង្ហាញនិន្នាការធ្លាក់ចុះចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១។ ក្នុងខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា បង្ហាញនិន្នាការចម្រុះធៀបនឹងខែធ្នូ ឆ្នាំ២០២១ ដែលតម្លៃត្រីផ្ទក់ និងសាច់ជ្រូកបានធ្លាក់ចុះ ឯតម្លៃប្រេងឆាបានកើនឡើង។ តម្លៃមធ្យមលក់រាយ**ត្រីផ្ទក់** គឺ ៩.៦៥១ រៀល/គក ថយចុះ **១,៣% បើធៀបនឹងខែមុន តែកើនឡើង ១០,១% បើធៀបនឹងខែដដែលកាលពីឆ្នាំមុន**។ តម្លៃមធ្យមលក់រាយ**សាច់ជ្រូក** គឺ ១៨.៣១០ រៀល/គក **ថយចុះ ២,១% បើធៀបនឹងខែមុន និង ១៤,៨% បើធៀបនឹងខែដដែលកាលពីឆ្នាំមុន**។ ផ្ទុយមកវិញ តម្លៃមធ្យមលក់រាយ**ប្រេងឆា** បន្តកើនឡើងដល់ ៣០.៩១៧ រៀល/៥លីត្រ **កើនឡើង ០,៧% បើធៀបនឹងខែមុន និង ៣៥,៩% បើធៀបនឹងខែដដែលកាលពីឆ្នាំមុន**។ សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។




*[1] ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារ

តម្លៃនៃកញ្ចប់ស្បៀងអាហារ[1] ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយពីផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែទៅលើតម្លៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។ តម្លៃនៃកញ្ចប់ស្បៀងអាហារជាមធ្យមមាននិន្នាការកើនឡើងក្នុងឆ្នាំ២០២១ ដោយតម្លៃបានហក់ឡើង២ដង - ក្នុងខែតុលា និងខែធ្នូ ឆ្នាំ២០២១ ដល់តម្លៃប្រមាណ ១១០.៩០០ រៀល/ម្នាក់/ខែ មុនពេលដែលវាធ្លាក់ចុះក្នុងខែមករា ឆ្នាំ២០២២។ **ក្នុងខែមករា ឆ្នាំ២០២២** តម្លៃមធ្យមនៃកញ្ចប់ស្បៀងអាហារគឺ **១០៣.៣៥៨** រៀល/ម្នាក់/ខែ ប្រហែល **២៥ ដុល្លារ (២៤ ដុល្លារ នៅជនបទ និង ២៦ ដុល្លារ នៅទីប្រជុំជន)** ដោយទាបជាងខែធ្នូ ឆ្នាំ២០២១ **៦,៩%** តែមិនមានការប្រែប្រួលទេបើធៀបនឹងខែដដែលកាលពីឆ្នាំមុន។ សូមមើលឧបសម្ព័ន្ធទី៣ ស្តីពីវិធីសាស្ត្រ។




*[1] កញ្ចប់ស្បៀងអាហារមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្ទក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ តម្រូវការថាមពលអប្បបរមាត្រូវបានដកស្រង់ចេញពីការសិក្សាពីកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ សូមមើលឧបសម្ព័ន្ធទី៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយស្បៀងអាហារទាំង៦ ដែលបរិភោគជាទូទៅ នៅជនបទ ទាបជាងទីប្រជុំជន លើកលែងប្រេងឆា (តារាង១)។ ចន្លោះខែធ្នូ ឆ្នាំ២០២១ និងខែមករា ឆ្នាំ២០២២ បម្រែបម្រួលតម្លៃមធ្យមលក់រាយស្បៀងសំខាន់ៗ លើកលែងប្រេងឆា នៅជនបទ និងទីប្រជុំជន មានទិសដៅដូចគ្នា។ តម្លៃប្រេងឆាកើនឡើង **៣,៣%** នៅជនបទ តែថយចុះ **០,៩%** នៅទីប្រជុំជន បើធៀបនឹងខែមុន។ តម្លៃអង្ករចម្រុះ ថយចុះ **១,១%** នៅជនបទ និង **០,៦%** នៅទីប្រជុំជន បើធៀបនឹងខែមុន។ តម្លៃសាច់ជ្រូក ថយចុះ **២,០%** នៅជនបទ និង **២,២%** នៅទីប្រជុំជន បើធៀបនឹងខែមុន។ តម្លៃត្រីផ្ទក់ ថយចុះ **៤,០%** នៅជនបទ និង **០,៨%** នៅទីប្រជុំជន បើធៀបនឹងខែមុន។ តម្លៃមធ្យមលក់រាយស៊ុតទាថយចុះ **៩,៧%** នៅជនបទ និង **១,៥%** នៅទីប្រជុំជន បើធៀបនឹងខែមុន។ តម្លៃមធ្យមលក់រាយត្រកួនថយចុះ **២៨,៣%** នៅជនបទ និង **២០,១%** នៅទីប្រជុំជន បើធៀបនឹងខែមុន។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | 2,030 | 2,005 |
| ត្រីផ្ទក់ (រស់) (គក) | 9,887 | 9,179 |
| សាច់ជ្រូក (គក) | 18,414 | 18,184 |
| ស៊ុតទា (១០គ្រាប់) | 4,852 | 4,476 |
| ប្រេងឆា (៥លីត្រ) | 30,417 | 31,750 |
| ត្រកួន (គក) | 3,255 | 2,838 |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែធ្នូ ឆ្នាំ២០២១ និង ខែមករា ឆ្នាំ២០២២




*សម្គាល់៖ ទិន្នន័យនេះទទួលបានពីផ្សារចំនួន៨៥។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*

# **ថ្នាក់ក្រោមជាតិ៖** បម្រែបម្រួលតម្លៃអង្ករចម្រុះ និងស៊ុតទា

**នៅខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយអង្ករចម្រុះនៅទូទាំងប្រទេស គឺ ២.០១៩ រៀល ក្នុងមួយគីឡូក្រាម។** តម្លៃអង្ករមានការប្រែប្រួលទៅតាមទីផ្សារ និងខេត្ត ដោយតម្លៃលក់រាយខ្ពស់ជាងគេបំផុត គឺ ២.៤៧៥ រៀល ស្ថិតនៅផ្សារព្រៃវែង ខេត្តព្រៃវែង គឺខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ២៣,០%។ តម្លៃលក់រាយទាបជាងគេបំផុត គឺ ១.៧០០ រៀល នៅផ្សារផ្អាវ ខេត្តកំពង់ចាម និង ផ្សារសួង ខេត្តត្បូងឃ្មុំ គឺទាបជាងតម្លៃមធ្យមថ្នាក់ជាតិ ១៥,៨%។ បម្រែបម្រួលតម្លៃក្នុងផ្សារផ្សេងទៀតមានបង្ហាញនៅលើផែនទីខាងក្រោម។

**នៅខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយស៊ុតទានៅទូទាំងប្រទេស គឺ ៤.៦៥១ រៀល ក្នុង១០គ្រាប់។** តម្លៃស៊ុតទាក៏មានការប្រែប្រួលទៅតាមទីផ្សារ និងខេត្តដែរ ដោយតម្លៃខ្ពស់ជាងគេបំផុត គឺ ៥.៥០០ រៀល ស្ថិតនៅផ្សារសែនមនោរម្យ ខេត្តមណ្ឌលគិរី (១៨,០% ខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ)។ តម្លៃទាបជាងគេបំផុត (៣.៩០០ រៀល) ស្ថិតនៅផ្សារព្រែកតូច ខេត្តកណ្ដាល (១៦,០% ទាបជាងតម្លៃមធ្យមថ្នាក់ជាតិ)។ បម្រែបម្រួលតម្លៃក្នុងផ្សារផ្សេងទៀតមានបង្ហាញនៅលើផែនទីខាងក្រោម។

## តម្លៃលក់រាយអង្ករចម្រុះ តាមបណ្ដាខេត្ត ធៀបនឹងតម្លៃមធ្យមថ្នាក់ជាតិ (ខែមករា ឆ្នាំ២០២២)




## តម្លៃលក់រាយស៊ុតទា តាមបណ្ដាខេត្ត ធៀបនឹងតម្លៃមធ្យមថ្នាក់ជាតិ (ខែមករា ឆ្នាំ២០២២)



# ថ្នាក់ក្រោមជាតិ៖ បម្រែបម្រួលតម្លៃត្រីផ្ទក់ និងប្រេងឆា

**នៅខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយត្រីផ្ទក់ (រស់) នៅទូទាំងប្រទេស គឺ ៩.៦៥១ រៀល ក្នុងមួយគីឡូក្រាម។** តម្លៃមានភាពខុសគ្នាទៅតាមទីផ្សារ និងខេត្ត ដោយតម្លៃលក់រាយខ្ពស់ជាងគេបំផុត (១៣.០០០ រៀល) ស្ថិតនៅផ្សារដងទង់ ខេត្តកោះកុង (៣៥,០% ខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ)។ តម្លៃលក់រាយទាបជាងគេបំផុត (៧.០០០ រៀល) ស្ថិតនៅផ្សារព្រៃទទឹង (កំពង់ចាម) ផ្សារក្រគរ (ពោធិ៍សាត់) និងផ្សារដូនកែវ (តាកែវ) (២៥,០% ទាបជាងតម្លៃមធ្យមថ្នាក់ជាតិ)។ បម្រែបម្រួលតម្លៃក្នុងផ្សារផ្សេងទៀតមានបង្ហាញនៅលើផែនទីខាងក្រោម។

**នៅខែមករា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយប្រេងឆានៅទូទាំងប្រទេស គឺ ៣០.៩១៧ រៀល ក្នុង៥លីត្រ។** តម្លៃខ្ពស់ជាងគេបំផុត (៣៤.៥០០ រៀល) ស្ថិតនៅផ្សារភ្នំស្រុក ខេត្តបន្ទាយមានជ័យ (១១,៦% ខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ)។ តម្លៃទាបជាងគេបំផុត (២៦.៥០០ រៀល) ស្ថិតនៅផ្សារលើ ខេត្តកំពង់ឆ្នាំង (១៤,០% ទាបជាងតម្លៃមធ្យមថ្នាក់ជាតិ)។ បម្រែបម្រួលតម្លៃក្នុងផ្សារផ្សេងទៀតមានបង្ហាញនៅលើផែនទីខាងក្រោម។

## តម្លៃលក់រាយត្រីផ្ទក់ តាមបណ្ដាខេត្ត ធៀបនឹងតម្លៃមធ្យមថ្នាក់ជាតិ (ខែមករា ឆ្នាំ២០២២)




## តម្លៃលក់រាយប្រេងឆា តាមបណ្ដាខេត្ត ធៀបនឹងតម្លៃមធ្យមថ្នាក់ជាតិ (ខែមករា ឆ្នាំ២០២២)



# ពាណិជ្ជកម្ម និងផលិតកម្មក្នុងស្រុក

បើទោះបីជាជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់មកលើសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០២១ ស្ថិតិសរុបនៃពាណិជ្ជកម្ម និងផលិតកម្មកសិកម្មនៅតែបង្ហាញវឌ្ឍនភាពជាវិជ្ជមាន។ ផ្អែកតាមរបាយការណ៍សភាពការណ៍កសិកម្មឆ្នាំ២០២១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ចេញផ្សាយថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ ផលិតកម្មដំណាំស្រូវវស្សាប្រមូលផល គិតត្រឹមខែធ្នូ ឆ្នាំ២០២១ សម្រេចបាន ៩,០៦ លានតោន ខ្ពស់ជាងឆ្នាំមុន ១០,២%។ ជាងនេះទៅទៀត ផ្ទៃដីដាំដុះដំណាំស្រូវប្រាំងសម្រេចបាន ៤៦៧.០៩៨ ហិកតា (ទាបជាងរយៈពេលដដែលកាលពីឆ្នាំមុន ៥,៨%។ ផ្ទៃដីដាំដុះដំណាំសារប្បកម្មសម្រេចបាន ២០.០៣៣ ហិកតា (-១៧,៤%)។ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មសម្រេចបាន ៤៨.១៩៦ ហិកតា (-៩,៧%)។

ក្នុងខែមករា ឆ្នាំ២០២២ កម្ពុជាបាននាំចេញស្រូវប្រមាណ ២៧៥.៥១១ តោន (មានតម្លៃស្មើ ៦០,៦១ លានដុល្លារ) (ទំព័រហ្វេសប៊ុកផ្លូវការរបស់សហព័ន្ធស្រូវអង្ករកម្ពុជា - CRF ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២)។ លើសពីនេះទៀត ការនាំអង្ករចេញសម្រេចបានចំនួន ៥៣,០៣៦ តោន (មានតម្លៃស្មើ ៣៥,៧២ លានដុល្លារ) ខ្ពស់ជាងរយៈពេលដដែលកាលពីឆ្នាំមុន ៥៤,៧៥%។ ប្រទេសចិននៅតែជាប្រទេសដែលស្រូបយកការនាំចេញអង្ករពីកម្ពុជាច្រើនជាងគេ (៥៨,៨%) បន្ទាប់មកគឺសហភាពអឺរ៉ុប (២៣,៦%) ប្រទេសក្នុងតំបន់អាស៊ាន (១១,៨%) និងប្រទេសចំនួន២៧ផ្សេងៗទៀត (៥,៧%) (ទំព័រហ្វេសប៊ុកផ្លូវការរបស់ CRF ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២)។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង (CKFTA) ត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ហើយរំពឹងទុកថានឹងចូលជាធរមានយ៉ាងយូរចុងខែមិថុនា ឆ្នាំ២០២២ (ដកស្រង់ដោយភ្នំពេញប៉ុស្ត៍ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២)។ ពាណិជ្ជកម្មរវាងកម្ពុជា និងកូរ៉េខាងត្បូងមានតម្លៃ ៩៦៥ លានដុល្លារ កាលពីឆ្នាំ២០២១ កើនឡើង ៩% ធៀបនឹងឆ្នាំ២០២០ (ដកស្រង់ដោយប្រេសញូវ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២២)។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ដែលបានចុះហត្ថលេខានៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ និង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីធំជាងគេបំផុតរវាងប្រទេសអាស៊ាន អូស្ត្រាលី នូវែលសេឡង់ ចិន ជប៉ុន និងកូរ៉េខាងត្បូង ដែលបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលជាធរមានកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ (ដកស្រង់ដោយ Xinhua News ថ្ងៃទី១ ខែមករា ឆ្នាំ២០២២ និង ព្រឹត្តិប័ត្រ iTrade លេខ ០១ របស់ក្រសួងពាណិជ្ជកម្ម ខែមករា ឆ្នាំ២០២២)។ ដូច្នេះ កិច្ចព្រមព្រៀងទ្វេភាគី រួមនឹង RCEP នឹងជំរុញការធ្វើពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសនានានៅក្នុងតំបន់ និងសកលលោក។

## ការនាំចេញអង្ករ គិតត្រឹមខែមករា ឆ្នាំ២០២២ តាមទិសដៅនាំចេញ




***ប្រភព៖*** *ទំព័រហ្វេសប៊ុកផ្លូវការរបស់សហព័ន្ធស្រូវអង្ករកម្ពុជា - CRF ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជាតិជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទូទាំងប្រទេស ក្នុងអំឡុងពេលការរាតត្បាតកូវីដ-១៩។ នាពេលថ្មីៗនេះ រដ្ឋាភិបាលបានសម្រេចបន្តអនុវត្តកម្មវិធីរយៈពេល៩ខែទៀត ដល់ខែកញ្ញា ឆ្នាំ២០២២។ គ្រួសារក្រីក្រប្រមាណ ៦៨៦.២០៥ គ្រួសារ (ប្រមាណ ២,៧ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ៥៦២,២២ លានដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃ២៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ (ទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ខែមករា ឆ្នាំ២០២២)។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

ផ្អែកតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) រដ្ឋាភិបាលបានត្រៀមថវិកាជាតិប្រមាណ ៧១៩ លានដុល្លារ សម្រាប់អន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ក្រោមសសរស្តម្ភចំនួន ៣៖ ការស្តារ ការកែទម្រង់ និងការកសាងភាពធន់ (MEF ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២) បន្ទាប់ពីបានចំណាយប្រមាណ ១.៦២៧ លានដុល្លារ ក្នុងឆ្នាំ២០២០ និង ២០២១ ទៅលើការការពារអាយុជីវិត និងរក្សាលំនឹងជីវភាពរបស់ប្រជាពលរដ្ឋ (ដកស្រង់ដោយ RFI ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២)។

នាពេលថ្មីៗនេះ MEF បានប្រកាសលើកលែងពន្ធលើអាករបន្ថែម (VAT) លើស្បៀងអាហារមូលដ្ឋាន ក្នុងរយៈពេល២ឆ្នាំ គិតចាប់ពីខែមករា ឆ្នាំ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៣ (ដកស្រង់ពីខ្មែរថាម ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២២)

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាមក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២ ពលរដ្ឋអាយុលើសពី៥ឆ្នាំ ប្រមាណ ១៤,៣៥ លាននាក់ (៧,២២ លាននាក់ ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិប្រមាណ ១០២,៣%។ ក្នុងចំណោមនោះ ប្រមាណ ១៣,៧៦ លាននាក់ (៦,៩១ លាននាក់ ជាស្ត្រី) បានទទួលវ៉ាក់សាំងដូសទី២រួចរាល់ ហើយលើសពី ៣,៦៥ លាននាក់ (២,៩០ លាននាក់ ជាស្ត្រី) បានទទួលវ៉ាក់សាំងដូសជំរុញទី៣ រួចរាល់ក្នុងខែនេះ។ រដ្ឋាភិបាលចាប់ផ្តើមផ្តល់វ៉ាក់សាំងដូសជំរុញទី៤ក្នុងខែមករា ឆ្នាំ២០២២ ហើយគិតត្រឹមខែនេះ ពលរដ្ឋចំនួន ៤៥៩.៩៣០ នាក់ (១៩៥.៩៧៩ នាក់ ជាស្ត្រី) បានទទួលដូសជំរុញទី៤រួចរាល់ហើយ។



ការលើកលែងពន្ធសម្រាប់ស្បៀងអាហារមូលដ្ឋាន ដូចជា បន្លែ សាច់ជ្រូក សាច់មាន់ សាច់ទា ស៊ុត ជាដើម ចូលជាធរមានចាប់ពីខែមករា ឆ្នាំ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៣។

*ប្រភព៖ ខ្មែរថាម ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២*

# វិធីសាស្ត្រ និងទីតាំងផ្សារ

## ទីផ្សារដែលបានប្រមូលទិន្នន័យ

World Food Programme




កម្មវិធីស្បៀងអាហារពិភពលោក ចាប់ផ្តើមតាមដានពីតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទតាំងពីខែវិច្ឆិកាឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានារៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៤ ក្នុងទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។

ក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនាឆ្នាំ២០២០ កម្មវិធីស្បៀងអាហារពិភពលោក បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១ទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្រប់ដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក កម្មវិធីស្បៀងអាហារពិភពលោកបានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

**ការិយាល័យទីផ្សារកសិកម្ម**
នាយកដ្ឋានផែនការនិងស្ថិតិ,
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://www.amis.org.kh/

**កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ**
ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះនៅក្នុងការិយាល័យប្រចាំប្រទេសកម្ពុជា
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# ឧបសម្ព័ន្ធទី១

## បម្រែបម្រួលតម្លៃលក់រាយ
## (ខែមករា ឆ្នាំ២០២២)

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែ (មករា២០២២) | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| 1.1. អង្ករចម្រុះ/ Mixed Rice | Riels/Kg | 2,019 | ► -0.8% | ► -3.9% | ► -2.9% |
| 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | Riels/Kg | 9,651 | ► -1.3% | ▼ -9.2% | ▲ 10.1% |
| 2.2. ត្រីប្រា(រស់)/ Trey Pra (Live) | Riels/Kg | 6,223 | ► -3.1% | ► -3.4% | ► -4.8% |
| 2.3. ត្រីអណ្តែង(រស់)/ Cat fish (Live) | Riels/Kg | 7,706 | ► -0.3% | ► 3.3% | ▲ 5.9% |
| 2.4. ត្រីផ្ទក់ងៀត/ Dried snake fish | Riels/Kg | 24,636 | ► 4.2% | ► -0.6% | ► 1.8% |
| 3.1. សាច់ជ្រូកពពជាន់/ 3-layer pork/Pork with fat | Riels/Kg | 18,310 | ► -2.1% | ▼ -7.6% | ▼ -14.8% |
| 4.1. ស៊ុតទា/Duck egg (Riels/10 eggs) | Riels/10 eggs | 4,651 | ▼ -5.8% | ▼ -18.3% | ▲ 5.9% |
| 4.2. ស៊ុតទាប្រៃ/Salty/Fermented duck egg | Riels/10 eggs | 6,467 | ► -0.1% | ▼ -5.7% | ▲ 8.3% |
| 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | Riels/ 5 litre | 30,917 | ► 0.7% | ▲ 11.1% | ▲ 35.9% |
| 6.1. អំបិលម៉ត់អ៊ីយូត/ Iodized salt | Riels/Kg | 1,222 | ▲ 6.6% | ► 4.1% | ▲ 8.7% |
| 7.1. សណ្តែកដី/ Ground Nut* | Riels/Kg | 9,262 | ► -2.8% | ▼ -5.3% | ▲ 6.4% |
| 8.1. ត្រកួន/ Morning glory | Riels/Kg | 3,097 | ▼ -23.1% | ▼ -7.5% | ▲ 7.3% |
| 8.2. ការ៉ុត/ Carrot* | Riels/Kg | 3,823 | ▼ -22.4% | ▲ 21.9% | ▲ 10.8% |
| 8.3. ស្លឹកបាស/ Ivy gourd leave* | Riels/Kg | 5,026 | ▼ -7.2% | ▲ 14.2% | ▼ -7.1% |
| 8.4. ស្លឹកម្រុំ/ Moringa leaves* | Riels/Kg | 5,000 | ▼ -5.4% | ▲ 14.1% | ► 2.6% |
| 8.5. ស្ពៃក្រញាញ់/ Chinese spinach* | Riels/Kg | 3,599 | ▼ -18.1% | ▼ -30.3% | ▲ 20.6% |
| 8.6. ស្ពៃតឿ/ Pak Choi* | Riels/Kg | 3,267 | ▼ -26.9% | ▼ -34.5% | ▲ 5.2% |
| 8.7. ស្ពៃចង្កឹះ/Chinese flowering cabbage | Riels/Kg | 2,970 | ▼ -21.7% | ▼ -23.5% | ▲ 14.6% |
| 8.8. ស្ពៃខៀវ/Mustard Greens* | Riels/Kg | 3,232 | ▼ -14.7% | ▼ -24.4% | ▲ 5.3% |
| 8.9. ផ្ទីដូង/ Amaranthus* | Riels/Kg | 4,121 | ▼ -15.5% | ► 0.7% | ▲ 22.1% |
| 8.10. ស្លឹកងប់/ Ngob leaves* | Riels/Kg | 6,750 | ▲ 16.5% | ▲ 38.3% | ▲ 33.5% |
| 8.11. ត្រួយល្ពៅ/ Pumpkin leaves* | Riels/Kg | 3,750 | ▼ -19.5% | ▼ -16.7% | ▼ -26.7% |
| 8.12. ផ្លែល្ពៅ/ Pumpkin fruit* | Riels/Kg | 2,636 | ► -3.0% | ▼ -10.3% | ▼ -15.0% |
| 8.13. ឃ្លោក/ Bottle gourd* | Riels/Kg | 2,028 | ▼ -17.0% | ▲ 27.7% | ▲ 8.1% |
| 8.14. ត្រឡាច/ Wax gourd | Riels/Kg | 3,128 | ► 4.0% | ▲ 30.9% | ▲ 49.0% |
| 8.15. ត្រប់វែង/ Long eggplants | Riels/Kg | 3,211 | ▼ -8.9% | ▲ 14.3% | ▲ 5.9% |
| 8.16. ត្រប់ស្រួយ/ Round eggplants* | Riels/Kg | 3,591 | ▼ -13.1% | ▲ 27.7% | ▲ 13.6% |
| 8.17. ប៉េងប៉ោះ/ Tomatoes* | Riels/Kg | 4,783 | ▼ -24.5% | ▲ 41.1% | ▲ 50.8% |
| 8.18. ននោងមូល/ Spong gourd | Riels/Kg | 2,947 | ► 0.5% | ▲ 15.5% | ▲ 10.0% |
| 8.19. ននោងជ្រុង/ Ridge Gourd* | Riels/Kg | 3,183 | ► -4.9% | ▲ 9.7% | ▲ 20.9% |
| 8.20. ល្ហុងខ្ចី/ Green papaya* | Riels/Kg | 1,424 | ► 4.3% | ▲ 16.5% | ► 4.0% |
| 8.21. សណ្តែកគួរ/ Long bean | Riels/Kg | 6,167 | ▲ 22.2% | ▲ 65.3% | ▲ 57.4% |
| 8.22. ត្រយូងចេក/ Banana flower* | Riels/Kg | 2,770 | ▲ 24.7% | ▲ 23.1% | ▼ -22.9% |
| 8.23. ផ្កាខាត់ណា/ Cauliflower* | Riels/Kg | 5,698 | ▼ -36.3% | ▼ -36.0% | ▲ 13.5% |
| 8.24. ដើមខាត់ណា/ Chinese Kale* | Riels/Kg | 4,596 | ▼ -35.8% | ▼ -24.5% | ▲ 10.7% |
| 8.25. ដំឡូងព័ណលឿង/ Orange-flesh Sweet Potatoes* | Riels/Kg | 2,413 | ▲ 11.5% | ► 4.7% | ► -4.9% |

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

▲ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%

► ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%

▼ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%

* តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្ត ដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍ គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែ (មករា២០២២) | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| 1.1. អង្ករចម្រុះ/ Mixed Rice | Riels/Kg | 1,873 | ▶ -0.9% | ▶ -4.5% | ▶ -3.5% |
| 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | Riels/Kg | 8,667 | ▶ -1.9% | ▼ -11.4% | ▲ 8.9% |
| 2.2. ត្រីប្រា(រស់)/ Trey Pra (Live) | Riels/Kg | 5,658 | ▶ -2.6% | ▶ -3.3% | ▶ -3.6% |
| 2.3. ត្រីអណ្តែង(រស់)/ Cat fish (Live) | Riels/Kg | 6,985 | ▶ -1.7% | ▶ 1.7% | ▲ 5.5% |
| 2.4. ត្រីផ្ទក់ងៀត/ Dried snake fish | Riels/Kg | 22,519 | ▶ 2.5% | ▶ -2.2% | ▶ -0.6% |
| 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | Riels/Kg | 16,831 | ▶ -1.7% | ▼ -8.3% | ▼ -16.1% |
| 4.1. ស៊ុតទា/Duck egg (Riels/10 eggs) | Riels/10 eggs | 4,183 | ▼ -7.2% | ▼ -20.8% | ▶ 4.5% |
| 4.2. ស៊ុតទាប្រៃ/Salty/Fermented duck egg | Riels/10 eggs | 5,927 | ▶ -0.8% | ▼ -9.0% | ▲ 6.0% |
| 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | Riels/ 5 litre | 30,100 | ▶ 0.3% | ▲ 10.7% | ▲ 36.0% |
| 6.1. អំបិលម៉ត់អ៊ីយូត/ Iodized salt | Riels/Kg | 999 | ▲ 5.3% | ▶ 1.4% | ▲ 8.5% |
| 7.1. សណ្តែកដី/ Ground Nut* | Riels/Kg | 8,543 | ▶ -2.7% | ▼ -6.1% | ▲ 5.1% |
| 8.1. ត្រកួន/ Morning glory | Riels/Kg | 2,525 | ▼ -25.7% | ▼ -12.2% | ▶ 4.4% |
| 8.2. ការ៉ុត/ Carrot* | Riels/Kg | 3,125 | ▼ -27.7% | ▲ 16.8% | ▲ 14.8% |
| 8.3. ស្លឹកបាស/ Ivy gourd leave* | Riels/Kg | 4,240 | ▼ -5.3% | ▲ 23.0% | ▶ -3.1% |
| 8.4. ស្លឹកម្រុំ/ Moringa leaves* | Riels/Kg | 4,636 | ▶ -0.6% | ▲ 23.8% | ▲ 15.5% |
| 8.5. ស្ពៃក្រញាញ់/ Chinese spinach* | Riels/Kg | 2,892 | ▼ -23.5% | ▼ -35.9% | ▲ 28.3% |
| 8.6. ស្ពៃតឿ/ Pak Choi* | Riels/Kg | 2,565 | ▼ -32.3% | ▼ -40.0% | ▲ 6.1% |
| 8.7. ស្ពៃចង្កឹះ/Chinese flowering cabbage | Riels/Kg | 2,376 | ▼ -26.3% | ▼ -28.9% | ▲ 11.9% |
| 8.8. ស្ពៃខៀវ/Mustard Greens* | Riels/Kg | 2,578 | ▼ -19.6% | ▼ -30.7% | ▲ 10.7% |
| 8.9. ផ្ទីដូង/ Amaranthus* | Riels/Kg | 3,346 | ▼ -21.2% | ▶ 0.7% | ▲ 45.1% |
| 8.10. ស្លឹកងប់/ Ngob leaves* | Riels/Kg | 6,583 | ▲ 26.6% | ▲ 67.9% | ▲ 61.2% |
| 8.11. ត្រួយល្ពៅ/ Pumpkin leaves* | Riels/Kg | 3,333 | ▼ -20.3% | ▼ -11.3% | ▼ -20.5% |
| 8.12. ផ្លែល្ពៅ/ Pumpkin fruit* | Riels/Kg | 2,106 | ▼ -7.2% | ▼ -14.9% | ▼ -13.9% |
| 8.13. ឃ្លោក/ Bottle gourd* | Riels/Kg | 1,783 | ▼ -13.3% | ▲ 21.9% | ▶ 4.9% |
| 8.14. ត្រឡាច/ Wax gourd | Riels/Kg | 2,667 | ▲ 5.6% | ▲ 35.9% | ▲ 66.4% |
| 8.15. ត្រប់វែង/ Long eggplants | Riels/Kg | 2,685 | ▼ -10.1% | ▲ 18.1% | ▶ 4.0% |
| 8.16. ត្រប់ស្រួយ/ Round eggplants* | Riels/Kg | 3,047 | ▼ -13.8% | ▲ 28.9% | ▲ 15.0% |
| 8.17. ប៉េងប៉ោះ/ Tomatoes* | Riels/Kg | 3,995 | ▼ -29.3% | ▲ 35.8% | ▲ 56.2% |
| 8.18. ននោងមូល/ Spong gourd | Riels/Kg | 2,559 | ▶ 3.4% | ▲ 18.1% | ▲ 17.0% |
| 8.19. ននោងជ្រុង/ Ridge Gourd* | Riels/Kg | 2,820 | ▶ 3.5% | ▲ 15.8% | ▲ 38.9% |
| 8.20. ល្ហុងខ្ចី/ Green papaya* | Riels/Kg | 1,056 | ▶ 0.3% | ▲ 10.5% | ▶ 2.4% |
| 8.21. សណ្តែកគួរ/ Long bean | Riels/Kg | 5,528 | ▲ 26.8% | ▲ 73.0% | ▲ 65.9% |
| 8.22. ត្រយូងចេក/ Banana flower* | Riels/Kg | 2,347 | ▲ 20.2% | ▲ 22.2% | ▼ -25.9% |
| 8.23. ផ្កាខាត់ណា/ Cauliflower* | Riels/Kg | 4,933 | ▼ -37.0% | ▼ -38.0% | ▲ 19.2% |
| 8.24. ដើមខាត់ណា/ Chinese Kale* | Riels/Kg | 3,859 | ▼ -39.0% | ▼ -29.6% | ▲ 14.5% |
| 8.25. ដំឡូងពណ៌លឿង/ Orange-flesh Sweet Potatoes* | Riels/Kg | 1,917 | ▲ 7.7% | ▶ 1.1% | ▼ -6.1% |

# ឧបសម្ព័ន្ធទី២

## បម្រែបម្រួលតម្លៃលក់ដុំ (ខែមករា ឆ្នាំ២០២២)

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

▲ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%

▶ ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%

▼ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%

* តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍ គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារ

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារ ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឲ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារ**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.02 | 25,362 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 9.65 | 26,722 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 18.31 | 22,670 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 7.44 | 2,681 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 6.79 | 2,652 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.10 | 21,833 |
| Tuber | Sweet Potato | 8.25. ដំឡូងពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.41 | 1,439 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **103,358** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឲ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ <u>មិនដូចគ្នា</u> ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីគម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ ខែមករា ឆ្នាំ២០២២ WFP ប្រចាំប្រទេសកម្ពុជា។*

# ឧបសម្ព័ន្ធទី៤៖ របាយប្រជាជន ផ្ទៃដីដាំដុះដំណាំស្រូវ និងប្រតិទិនរដូវកាល

## របាយប្រជាជន




ប្រភព៖ LandScan™ Global ត្រូវបានផលិតឡើងដោយ Oak Ridge National Laboratory ឆ្នាំ2019

## ផ្ទៃដីដាំដុះដំណាំស្រូវ




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ2008

## ប្រតិទិនរដូវកាល

| | | | | | |
|---|---|---|---|---|---|
| ស្រូវប្រាំង | ដាំដុះ | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | |
| ស្រូវវស្សា | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | ស្ទូង / ដាំដុះ | ប្រមូលផល |

| មករា 2021 | កុម្ភៈ 2021 | មីនា 2021 | មេសា 2021 | ឧសភា 2021 | មិថុនា 2021 | កក្កដា 2021 | សីហា 2021 | កញ្ញា 2021 | តុលា 2021 | វិច្ឆិកា 2021 | ធ្នូ 2021 |
|---|---|---|---|---|---|---|---|---|---|---|---|
| រដូវប្រាំង | | | | រដូវវស្សា | | | | | | រដូវប្រាំង | |